# របាយការណ៍ប្រចាំខែមេសា ឆ្នាំ ២០១៧ របស់គម្រោង IPLR, RIP

គម្រោងសហហិរញ្ញប្បទានឥតសំណង រវាងរដ្ឋាភិបាលសាធារណរដ្ឋ សហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងព្រះរាជាណាចក្រកម្ពុជា ដែលបាននឹងកំពុងអនុវត្តដោយ អង្គភាពគ្រប់គ្រងគម្រោង នៃក្រសួងអភិវឌ្ឍន៍ជនបទ មានចំនួន ០២ គម្រោង និងការងារថែទាំខួបដែលប្រើប្រាស់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាល សម្រាប់ឆ្នាំ ២០១៧ ដូចខាងក្រោមៈ

## I. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីធានាចីរភាពក្នុងការអនុវត្តកំណែទម្រង់ដីធ្លី

**(Economic Infrastructure Programme to Sustain Land Reform Implementation "IPLR")**

IPLR ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW ដែលមានទឹកប្រាក់ចំនួន **៩ លានអឺរ៉ូ** និងប្រាក់បដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន **០.៩ លានអឺរ៉ូ ឬស្មើនឹង ១០%**។ គម្រោងនេះជាគម្រោងដែលបានបង្វែរការអនុវត្តការងារពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយបាននឹងកំពុងអនុវត្តលើខេត្តចំនួន ០៥ សម្រាប់រយៈពេល ៣ឆ្នាំ (២០១៥-២០១៧) និងចែកចេញជា ២វគ្គគឺៈ វគ្គទី ១ អនុវត្តលើខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ និងវគ្គទី ២ អនុវត្តលើខេត្តក្រចេះ រតនគិរី និងមណ្ឌលគិរី។ គម្រោងនេះផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើៈ

- ការសាងសង់ផ្លូវថ្មីជនបទ
- ការសាងសង់សាលារៀន
- ការសាងសង់ស្ពាន និងលូផ្សេងៗ
- ការជីកអណ្តូង ។ល។

### I.1 លទ្ធផលការងារសម្រេចបានក្នុងវគ្គទី ១÷

### ក. ខេត្តកំពង់ឆ្នាំង

### ក.១. ការងារសាងសង់ផ្លូវ

- បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម ១ខ្សែ មានកិច្ចសន្យាលេខ IPLR-CHH-LOT1 ប្រវែងសរុប 10.665 km. ពីភូមិតាំងគ្រួស ទៅភូមិសំបុកគ្រៀល ក្នុងឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ
- បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម ១ខ្សែ មានកិច្ចសន្យាលេខ IPLR-CHH-LOT2 ប្រវែងសរុប 9.620 km ដែល 1.120 Km. ស្ថិតក្នុងភូមិកុលមានជ័យនិងភូមិសុខសែនជ័យ ក្នុងឃុំឈូកនិងឃុំពាម, 4.450 Km. ស្ថិតក្នុងភូមិខ្សាច់សនិងភូមិកុលមានជ័យ ក្នុងឃុំក្រាំងល្វានិងឃុំស្វាយជុក, 3.350 Km. ស្ថិតក្នុងភូមិសុខសែនជ័យនិងគីរីអភិវឌ្ឍន៍ ក្នុងឃុំពាមនិងឃុំឈានឡើង និង 0.700 km. ស្ថិតក្នុងភូមិឈានឡើង ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ។

### ក.២. ការងារសាងសង់អណ្តូង

យោងតាមការណែនាំរបស់ម្ចាស់ជំនួយ អង្គភាពគ្រប់គ្រងគម្រោងបានចុះកិច្ចសន្យា និងប្រគល់កិច្ចសន្យាជូនអង្គការជីវិតថ្លៃថ្នូរ (Life With Dignity "LWD") កាលពីថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៦ មានទឹកប្រាក់សរុបចំនួន ៣៤,២០០ (សាមសិបបួនពាន់ ពីររយដុល្លាសហរដ្ឋអាមេរិក) ដើម្បីសាងសង់អណ្តូងស្នប់ (AFRIDEF) ចំនួន ១២ ស្ថិតនៅភូមិសុខសែនជ័យ ខ្សាច់ស សំបុកគ្រៀល ក្នុងឃុំក្រាំងល្វានិងឃុំពាម ស្រុកសាមគ្គីមានជ័យ ហើយគ្រោងបញ្ចប់នៅចុងខែ ឧសភា ឆ្នាំ ២០១៧ ខាងមុខ។

**ខ. ខេត្តកំពង់ធំ**

**ខ.១. ការងារសាងសង់ផ្លូវ**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលក្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ១ ខ្សែ មានកិច្ចសន្យាលេខ IPLR-KPT-LOT1 ប្រវែងសរុប ២៣.១០០គម. ដែល ១០.៦៧០គម. ស្ថិតក្នុងភូមិទីពោ និងភូមិស្រែស្រម៉ ក្នុងឃុំទីពោ និង ១២.៤៣១គម. ស្ថិតក្នុងភូមិធម្មនាថនិងភូមិទីពោ ក្នុងឃុំតាំងក្រសាំង និងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ សម្រេចបានប្រមាណ ៩៥ %។

**ខ.២. ការងារសាងសង់អណ្តូង**

- ដូចបានចែងក្នុងចំនុច "ក.២" ខាងលើ សម្រាប់ខេត្តកំពង់ធំ យើងទទួលបានអណ្តូងល្ង (Shallow Well) ចំនួន ២៤ ដែលមានទីតាំងស្ថិតនៅ ភូមិសែនអភិវឌ្ឍន៍ សែនអភិវឌ្ឍន៍២ អូរធំ ក្នុងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ហើយគ្រោងបញ្ចប់នៅចុងខែ ឧសភា ឆ្នាំ ២០១៧ ខាងមុខដូចគ្នា។

**I.2 លទ្ធផលការងារសម្រេចបានក្នុងវគ្គទី ២÷**

**ក. ខេត្តក្រចេះ**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម ១ខ្សែ មានកិច្ចសន្យាលេខ IPLR-KCH-LOT1 ប្រវែងសរុប 12.000 km. ពីកាកុត ដល់ក្បាលជ្ជរ ក្នុងដីសម្បទានសង្គមកិច្ច "សំបុក" ស្ថិតក្នុងភូមិកាកុត និងភូមិក្បាលជ្ជរ ឃុំសំបុក ស្រុកចិត្របូរី ខេត្តក្រចេះ សម្រេចបានប្រមាណ ៨០ %
- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម ១ខ្សែ មានកិច្ចសន្យាលេខ IPLR-KCH-LOT2 ប្រវែងសរុប 10.800 km. ពីអង្គចាន់ ដល់ចក ក្នុងដីសម្បទានសង្គមកិច្ច "ដារ" ស្ថិតក្នុង ឃុំដារ ស្រុកចិត្របូរី ខេត្តក្រចេះ សម្រេចបានប្រមាណ ៨០ %។

**ខ. ខេត្តកំពង់ឆ្នាំង**

- បាននឹងកំពុងសាងសង់សាលាបឋមសិក្សាចំនួន ១ខ្នង ស្មើនឹង ៣បន្ទប់ ស្ថិតក្នុងភូមិសំបុកគ្រៀល ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ សម្រេចបានប្រមាណ ៩០ %។

**គ. ខេត្តមណ្ឌលគិរី**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម ១ខ្សែ មានកិច្ចសន្យាលេខ IPLR-MKR-LOT1 ប្រវែងសរុប 8.672 Km. ពីផ្លូវជាតិលេខ ៧៦ ទៅកែវសីមា ស្ថិតក្នុងឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី សម្រេចបានប្រមាណ ៨៥ %
- បាននឹងកំពុងសាងសង់សាលាបឋមសិក្សាចំនួន ០១ខ្នង ស្មើនឹង ៥បន្ទប់ ស្ថិតក្នុងភូមិស្រែខ្ទុម ឃុំស្រែខ្ទុម ស្រុកកែវសីមា សម្រេចបានប្រមាណ ៩០ %។

**ឃ. ខេត្តរតនគីរី**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម ១ខ្សែ ប្រវែង 700 ម. នៅភូមិក្រឡា ឃុំប៉ូយ ស្រុកអូរជុំ សម្រេចបានប្រមាណ ៩០ %
- បាននឹងកំពុងសាងសង់សាលាបឋមសិក្សាចំនួន ១ខ្នង ស្មើនឹង ៣បន្ទប់ ស្ថិតក្នុងភូមិឡាអ៊ុនស្រែ ឃុំតឺន ស្រុកកូនមុំ សម្រេចបានប្រមាណ ៩០ %។

## II. កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ជំហានទី ៤

(Rural Infrastructure Programme Phase IV " RIP-IV")

RIP-IV ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា ដែលមានទឹកប្រាក់ដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW មានទឹកប្រាក់ចំនួន **១១ លានអឺរ៉ូ** និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន **១.១ លានអឺរ៉ូ** ឬស្មើនឹង ១០% ដោយអនុវត្តលើខេត្តចំនួន ៤ គឺៈ ខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និង ខេត្តព្រះវិហារ
- និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន **៣.៣** លានដុល្លារសហរដ្ឋអាមេរិកទៀត សម្រាប់ការងារថែទាំប្រចាំឆ្នាំ ដែលមានរយៈពេលរំកិល ៣ឆ្នាំ បន្តបន្ទាប់ (២០១៨-២០២០) ហើយនឹងអនុវត្តលើខេត្តចំនួន ១២គឺ ខេត្តបាត់ដំបង់ បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ សៀមរាប ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ និងខេត្តក្រចេះ។

**១. លទ្ធផលការងារសម្រេចបាន÷**

**ក. ខេត្តបន្ទាយមានជ័យ**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ០១ ខ្សែ ប្រវែងសរុប ១០.០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-BMC04 ដែលក្នុងនោះ ១.៤០ គ.ម ជាផ្លូវប្រភេទ DBST និង ៨.៦០ គ.ម ជាផ្លូវក្រាលគ្រួសក្រហម លាតសន្ធឹងពីភូមិតាបោ ដល់ភូមិក្វាវ ឃុំបុស្សូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ សម្រេចបានប្រមាណ ៣០%
- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ២៣.២០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-BMC06 ដែលក្នុងនោះ ២២.៣០ គ.ម ជាផ្លូវ ប្រភេទ

DBST និង ០.៩០ គ.ម ជាផ្លូវក្រាលគ្រួសក្រហម លាតសន្ធឹងពីភូមិត្រាង ឃុំភ្នំដី ដល់ភូមិធ្នង់ត្បូង ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យសម្រេចបានប្រមាណ ១៦%។

**ខ. ខេត្តបាត់ដំបង**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ១ ខ្សែ ប្រវែងសរុប ២២.២០០គម. មានកិច្ចសន្យាលេខ NCB-RIPIV-BTB02 ដែលក្នុងនោះ ២.៤០០ គ.ម ជាផ្លូវប្រភេទ DBST, ១៩.៨០០ គ.ម ជាផ្លូវក្រាលគ្រួសក្រហម លាតសន្ធឹងពីភូមិព្រះផុស ឃុំតាស់ក្រឡ ដល់ភូមិបឹងបី ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង សម្រេចបានប្រមាណ ៤៥ %
- បាននឹងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ១ ខ្សែ ប្រវែងសរុប ៥.២០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-BTB03 លាតសន្ធឹងពីភូមិជ្រៃ ២ ឃុំជ្រៃ ដល់ភូមិអង្ក្រង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង សម្រេចបានប្រមាណ ៣០ %
- បាននឹងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ៩.២០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-BTB04 លាតសន្ធឹងពីភូមិកគោ ឃុំអូរតាគី ដល់ភូមិប្រាសាទឯកភ្នំ ឃុំឯកភ្នំ ស្រុកថ្មគោល និងស្រុកពាមឯក ខេត្តបាត់ដំបង សម្រេចបានប្រមាណ ១៥ %។

**គ. ខេត្តឧត្តរមានជ័យ**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ១៦.០០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-OMC03 ដែលក្នុងនោះ ២.១០០ គ.ម ជាផ្លូវប្រភេទ DBST និង ១៣.៩០០គ.ម ជាផ្លូវក្រាលគ្រួសក្រហម លាតសន្ធឹងពីភូមិជើងទៀន ដល់ភូមិតាណូក ឃុំជើងទៀន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ សម្រេចបានប្រមាណ ៣៥ %។

**ឃ. ខេត្តព្រះវិហារ**

- បាននឹងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ១៦.៨០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-PVH01 លាតសន្ធឹងពីភូមិ ស្វាយប៉ាត ឃុំរំដោះ ដល់ភូមិស្ដៅ ឃុំស្ដៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ សម្រេចបានប្រមាណ ១១ %
- បាននឹងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ១២.៩០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-PVH03-1 លាតសន្ធឹងពីភូមិក្រាំងដូង ឃុំព្រះឃ្លាំង ដល់ភូមិដូនម៉ា ឃុំរក្សា ស្រុកត្បែងមានជ័យនិងស្រុករវៀង ខេត្តព្រះវិហារ សម្រេចបានប្រមាណ ២៥ %
- បាននឹងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ប្រវែងសរុប ១៩.០០០ គ.ម មានកិច្ចសន្យាលេខ NCB-RIPIV-PVH03-2 លាតសន្ធឹងពីភូមិក្រវ៉ាន់ ឃុំពុទ្រា ដល់ភូមិស្អាង ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ សម្រេចបានប្រមាណ ១១ %។

## III. ការងារថែទាំខួបឆ្នាំ ២០១៧÷

ការងារថែទាំឆ្នាំ ២០១៧ ជាផ្នែកមួយនៃការចូលរួមប្រាក់បដិភាគប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន ២,២ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ជំហានទី ៣ RIP-III) ដែលការ

ចូលរួមនេះ មានរយៈពេល ៣ឆ្នាំ (២០១៥ -២០១៧)។ សម្រាប់ឆ្នាំ ២០១៧ អង្គភាពគ្រប់គ្រងគម្រោង បានធ្វើការថែទាំផ្លូវជាលក្ខណៈខួប លើខ្សែផ្លូវសរុបប្រវែង ១៨៦.៦១៦ គ.ម ដូចខាងក្រោម៖

**ក.ខេត្តកំពង់ស្ពឺ (៣៣.២០០គម.)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KPS-RPM-13 ប្រវែងសរុប ២០.៥៤០ គ.ម ស្ថិតក្នុងពីភូមិតានីនិងភូមិដុំខ្ចិត ក្នុងឃុំក្រាំងចេកនិងឃុំវាលពង់ ស្រុកឧត្តុង្គនិងស្រុកថ្ពង សម្រេចបាន ១០០%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KPS-RPM-14 ប្រវែងសរុប ១២.៦៦០ គ.ម ដែល ៨.៤០០គ.ម ស្ថិតក្នុងភូមិបន្ទាយខ្មែរនិងភូមិត្រាចគង់ ក្នុងឃុំជើងរាស់និងឃុំយុទ្ធសាមគ្គី, និង ៤.២៦០គ.ម ស្ថិតក្នុងភូមិបន្ទាយខ្មែរនិងយសជួរ ក្នុងឃុំជើងរាស់ ស្រុកឧត្តុង្គ សម្រេចបាន ១០០%។

**ខ.ខេត្តកំពង់ឆ្នាំង (៣៦.៥០០គម.)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-CHH-RPM-16 ប្រវែងសរុប ១៨.៤០០ គ.ម ដែល ៤.០០០គ.ម ស្ថិតក្នុងភូមិគីរីអភិវឌ្ឍន៍និងភូមិអន្លង់ព្រីង ២.៥០០គ.ម ស្ថិតក្នុងភូមិអន្លង់ព្រីងនិងភូមិជួញជិត ៣.៤០០គ.ម ស្ថិតក្នុងភូមិត្រែងនិងអន្លង់ព្រីង និង ៨.៥០០គ.ម ស្ថិតក្នុងភូមិច្រកត្នោតនិងភូមិច្រកស្តេច ក្នុងឃុំឈានឡើងនិងឃុំពាម ស្រុកសាមគ្គីមានជ័យ សម្រេចបាន ៩០%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-CHH-RPM-17 ប្រវែងសរុប ១៨.១០០គ.ម ដែល ៣.៨០០គ.ម ស្ថិតក្នុងភូមិទំពបោះនិងភូមិថ្មស ក្នុងឃុំធ្លកវៀននិងឃុំខ្នារឆ្មារ ៣.៥០០គ.ម ស្ថិតក្នុងភូមិវត្តនិងភូមិជ្រៃកោងលិច ក្នុងឃុំខ្នារឆ្មារ ៣.៥០០ គ.ម ស្ថិតក្នុងភូមិវត្ត ក្នុងឃុំខ្នារឆ្មារ ២.៧០០ គ.ម ស្ថិតក្នុងភូមិខ្នារកណ្តាលនិងភូមិវត្ត ក្នុងឃុំខ្នារឆ្មារ និង៤.៦០០គ.ម ស្ថិតក្នុងភូមិថ្នល់និងភូមិជ្រៃកោងលិច ក្នុងឃុំក្រាំងល្វានិងឃុំខ្នារឆ្មារ ស្រុកសាមគ្គីមានជ័យ សម្រេចបាន ៩០%។

**គ.ខេត្តព្រៃវែង (១៨.២៦៦គម.)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-PRV-RPM-10 ប្រវែងសរុប ១០.០៩០គ.ម ដែល ៣.១៤០គ.ម ស្ថិតក្នុងភូមិព្រាលមួយនិងភូមិថ្មពូន ក្នុងឃុំថ្មពូន និង ៧.០៥០គ.ម ស្ថិតក្នុងភូមិតាប៉ោងនិងភូមិត្រពាំងពី ក្នុងឃុំថ្មពូននិងឃុំគោកគង់លិច ស្រុកកញ្ច្រៀច សម្រេចបាន ១០០%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-PRV-RPM-11 ប្រវែងសរុប ៨.១៧៦ គ.ម ដែល ៤.៦៥៩ គ.ម ស្ថិតក្នុងភូមិឆ្អឹងជំនីរនិងភូមិត្រពាំងឫស្សី ក្នុងឃុំគោគគង់លិចនិង ៣.៥១៧គ.ម ស្ថិតក្នុងភូមិត្នោតនិងភូមិកក់ ក្នុងឃុំត្នោត ស្រុកកញ្ច្រៀច សម្រេចបាន ១០០%។

**ឃ.ខេត្តកំពង់ចាម (២០.៨០០គ.ម)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KPC-RPM-23 ប្រវែងសរុប ២០.៨០០គ.ម លាតសន្ធឹងពីភូមិពោស្នាង (RN.6) ដល់ភូមិសំពងជ័យ ក្នុងឃុំសណ្តែកនិងឃុំសំពងជ័យ ស្រុកបាធាយនិងស្រុកជើងព្រៃ សម្រេចបាន ៨០%។

**ង.ខេត្តកំពង់ធំ (១៦.៧០០គ.ម)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KPT-RPM-17 ប្រវែងសរុប ១៦.៧០០ គ.ម ដែល ១២.០០០ គ.ម ស្ថិតក្នុងភូមិបុស្សចំបក់និងភូមិទំនប់ ឃុំទីពោ, និង ៤.៧០០ គ.ម ស្ថិតក្នុងភូមិតាំងក្រសាំង (RN.6) និងភូមិញ្ញោ ក្នុងឃុំតាំងក្រសាំងនិងឃុំញ្ញោ ស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ សម្រេចបាន ៨0%។

**ច. ខេត្តសៀមរាប (១៩.៩៥០គ.ម)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-SRP-RPM-15 ប្រវែងសរុប ១១.០០០ គ.ម ស្ថិតក្នុងភូមិចកនិងភូមិត្រពាំងរុន ក្នុងឃុំសង្វើយនិងឃុំឫស្សីឡោក ស្រុកជីក្រែង សម្រេចបាន ១០០%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-SRP-RPM-16 ប្រវែងសរុប ៨.៩៥០ គ.ម ស្ថិតក្នុងភូមិដូរតន្ត្រីនិងភូមិសរសៃពង ក្នុងឃុំកំពង់ថ្កូវនិងឃុំតាអាន ស្រុកក្រឡាញ់ សម្រេចបាន ១០០%។

**ឆ. ខេត្តត្បូងឃ្មុំ (១៥.៥០០គម.)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-TKM-RPM-04 ប្រវែងសរុប ៨.៥០០គ.ម ស្ថិតក្នុងភូមិព្រះអង្គនិងភូមិតាពេញ ក្នុងឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ សម្រេចបាន ១០០%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-TKM-RPM-05 ប្រវែងសរុប ៧.០០០គ.ម ស្ថិតក្នុងភូមិក្របីក្រៀកនិងភូមិបារាយ៍ ក្នុងឃុំឈូក ស្រុកស្រុកឆ្មារ សម្រេចបាន ១០០%។

**ជ. ខេត្តក្រចេះ (២៥.៧០០គម.)**

- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KCH-RPM-14 ប្រវែងសរុប ១២.៧០០ គ.ម ស្ថិតក្នុងភូមិច្នៃនិងភូមិព្រហូត ក្នុងឃុំឆ្លូងនិងឃុំដំរីផុង ស្រុកឆ្លូង សម្រេចបាន ៧0%
- បានថែទាំផ្លូវជាលក្ខណៈខួប ១ ខ្សែ មានកិច្ចសន្យាលេខ NCB-KCH-RPM-15 ប្រវែងសរុប ១៣.០០០ គ.ម ស្ថិតក្នុងភូមិព្រហូតនិងភូមិវាលកន្សែង ក្នុងឃុំដំរីផុងនិងឃុំកំពង់ដំរី ស្រុកឆ្លូង សម្រេចបាន ១០០%

**អគ្គនាយករងបច្ចេកទេស**

**និងជានាយកគម្រោង**RIP-II/FRRI